ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

លេខ...០៧៨/...គ.ជ.ក
/២១

# របាយការណ៍ខែមីនា
# ស្តីពី
# ការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ
# និងទិសដៅខែមេសា ឆ្នាំ២០២១

## I. ស្ថានភាពទូទៅ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់ក្រសួង ស្ថាប័ន រាជធានី ខេត្ត បានបន្តសកម្មភាព របស់ខ្លួនទៅតាមទិសដៅគ្រោងទុក បើទោះបីជាបាននិងកំពុងតែប្រឈមនឹងសភាពការណ៍វិវត្តថ្មី ដែលមិនអាចប៉ាន់ស្មានបាន ពាក់ព័ន្ធនឹងស្ថានភាពប្រែប្រួលនៃសេដ្ឋកិច្ចពិភពលោក និងបន្ថែមដោយវិបត្តិនៃការរាតត្បាតដោយជំងឺកូវីដ១៩។

ក្រសួង ស្ថាប័ន និងរាជធានី ខេត្ត បានបន្តទិសដៅការងារ ផ្តោតការយកចិត្តទុកដាក់បន្ថែម ទៅលើបញ្ហាវិបត្តិកូវីដ១៩ ដែលជាភាពប្រឈមថ្មី និងដែលជះឥទ្ធិពលដល់ការអនុវត្តសកម្មភាពគ្រប់វិស័យ ធ្វើឱ្យរាំងស្ទះដោយអន្លើ និងត្រូវបន្ថែមភារកិច្ច ក្នុងការដោះស្រាយទប់ស្កាត់ផលប៉ះពាល់ លើជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសអ្នកដែលវិលត្រឡប់ពីប្រទេសក្រៅ ដែលមានចំនួនច្រើនលើសលប់ និងភាគច្រើន ជាអ្នកដែលខ្វះលទ្ធភាព ក្នុងការទ្រទ្រង់ជីវភាព ហើយងាយរងគ្រោះ។ ការជួយសង្គ្រោះពលករដែលវិលត្រឡប់មកពីក្រៅប្រទេស គឺជាកិច្ចការចាំបាច់ ដើម្បីបង្ការទប់ស្កាត់ ការនាំចូលជំងឺកូវីដ១៩ ទៅក្នុងសហគមន៍ និងការដោះស្រាយភាពប្រឈមក្នុងពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ ព្រមទាំងទប់ស្កាត់ការចាញ់បោកមេខ្យល់ ក្នុងការនាំពលករត្រឡប់ទៅប្រទេសគោលដៅវិញ ក្នុងស្ថានភាពដែលមានការរឹតបន្តឹងពីប្រទេសគោលដៅ ដើម្បីការពារជំងឺរាតត្បាត និងវិបត្តិសេដ្ឋកិច្ចដែលកើតមានទូទាំងពិភពលោក ដែលធ្វើឱ្យពលករខាតបង់រឹតតែធ្ងន់ធ្ងរ និងធ្លាក់ទៅក្នុងរលកថ្មីនៃអំពើជួញដូរមនុស្ស។

អាជ្ញាធរ សមត្ថកិច្ច និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ និងអង្គការដៃគូ បានធ្វើសកម្មភាពយ៉ាងមមាញឹក ប្រចាំការនៅតាមព្រំដែនទទួលសង្គ្រោះពលករ ដែលវិលត្រឡប់តាមច្រកមិនផ្លូវការ ទាំងយប់ទាំងថ្ងៃ ពិនិត្យកម្តៅ និងផ្តល់សេវាសុខភាព អនុវត្តគោលការណ៍ចត្តាឡីស័កតាមវិធានសុខាភិបាល ផ្តល់អាហារ ត្រៀមមធ្យោបាយដឹកជញ្ជូន ឱ្យបានដល់លំនៅដ្ឋាន និងបន្តតាមដានស្ថានភាពសុខភាពជីវភាព និងផ្តល់សេវាតាមតម្រូវការផ្សេងៗ និងបន្តតាមដានស្ថានភាព នៅពេលធ្វើសមាហរណកម្មទៅក្នុងសហគមន៍ដែលពួកគាត់រស់នៅ។ លើសពីនេះទៅទៀត វិធានការអប់រំ បង្ការទប់ស្កាត់សកម្មភាពវិលត្រឡប់ទៅប្រទេសថៃវិញ ក្នុងអំឡុងពេលដែលមានការរឹតបន្តឹង ពីប្រទេសគោលដៅក្នុងវិធានការទប់ស្កាត់វិបត្តិកូវីដ១៩ និងដោះស្រាយវិបត្តិសេដ្ឋកិច្ច ការបង្កើនការស៊ើបអង្កេតរកមេខ្យល់ជួញដូរមនុស្ស ក្នុងដំណាក់កាលនេះ ការផ្តល់សេវាជួយជនរងគ្រោះ និងជនងាយរងគ្រោះ ត្រូវបានធ្វើឡើងកាន់តែសកម្ម។

ដើម្បីឆ្លើយតបទៅនឹងបញ្ហាដែលកើតមានខាងលើនេះ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ជាសេនាធិការ បានបង្កើនការយកចិត្តទុកដាក់ សម្របសម្រួលពង្រឹងកិច្ចសហការជាមួយក្រសួង ស្ថាប័ន ជាសមាជិក និងជំរុញសកម្មភាពគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរាជធានី-ខេត្ត មន្ទីរ អង្គភាព និងដៃគូជាតិ អន្តរជាតិ ក៏ដូចជាសមត្ថកិច្ចនៃប្រទេសពាក់ព័ន្ធ ដើម្បីធ្វើសកម្មភាព និងកិច្ចប្រតិបត្តិការដើម្បីដោះស្រាយបញ្ហារួមគ្នា ដោយទទួលបានលទ្ធផល ដូចខាងក្រោម៖

## II. លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស

### ក. ការងារ ច្បាប់ គោលនយោបាយ លិខិតបទដ្ឋានគតិយុត្ត ការអនុវត្តច្បាប់ និងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ

#### ក.១. ការកសាងច្បាប់

- ក្រសួងយុត្តិធម៌ និងក្រសួងកិច្ចការនារី បានដឹកនាំធ្វើសេចក្តីព្រាងច្បាប់ ស្តីពី"ការពពោះជំនួស"។
- ក្រសួងយុត្តិធម៌៖ បានរៀបចំសេចក្តីព្រាងច្បាប់ស្តីពី "ការប្រឆាំងអំពើរត់ពន្ធមនុស្ស"។

#### ក.២. សន្ធិសញ្ញា

- ក្រសួងយុត្តិធម៌
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសឡាវ បារាំង និងប្រទេសកូរ៉េខាងត្បូង ស្តីពី"ការជួយគ្នាទៅវិញទៅមកក្នុងវិស័យព្រហ្មទណ្ឌ"
  - បានកំពុងរៀបចំសេចក្តីព្រាងសន្ធិសញ្ញាទ្វេភាគី ជាមួយប្រទេសអង់គ្លេស ប៉េរូ និងប្រទេសឡាវ ស្តីពី "ការបញ្ជូនទណ្ឌិត"។

#### ក.៣. គោលនយោបាយ និងអនុស្សរណៈនៃការយោគយល់គ្នា

- ក្រសួងទេសចរណ៍ ត្រៀមចុះអនុស្សរណៈនៃការយោគយល់គ្នា ស្តីពីការអនុវត្តគម្រោងកុមារភាព ជាមួយអង្គការ Friends International។

#### ក.៤. លិខិតបទដ្ឋានគតិយុត្ត

- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖ ធ្វើសេចក្តីព្រាងរៀបចំអនុក្រឹត្យ ស្តីពីរបបគោលនយោបាយសម្រាប់ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចគ្រប់ទម្រង់ផ្សេងៗទៀត ដែលស្នាក់នៅមណ្ឌលសំចតរបស់រដ្ឋ និងរស់នៅតាមសហគមន៍។

#### ក.៥ ការពង្រឹងកិច្ចសហប្រតិបត្តិការ

- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានបន្តរៀបចំ និងចូលរួមអនុវត្តគម្រោងរួមគ្នា រវាងរាជរដ្ឋាភិបាល និងអង្គការសហប្រជាជាតិ សម្រាប់ពលករវិលត្រឡប់ ក្នុងដំណាក់កាល នៃការរាតត្បាតដោយជំងឺកូវីដ១៩ នៅក្នុងខេត្ត បាត់ដំបង សៀមរាប និងបន្ទាយមានជ័យ ។

### ខ. ការបង្ការ ទប់ស្កាត់

#### ខ.១. តាមរយៈការលើកកម្ពស់ការយល់ដឹង

##### ខ.១.១. ការអប់រំដោយផ្ទាល់តាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

នៅក្នុងខែមីនា ឆ្នាំ២០២១នេះ ស្ថាប័នថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ អាជ្ញាធរ មន្ទីរពាក់ព័ន្ធ បានសហការជាមួយអង្គការដៃគូ ធ្វើការផ្សព្វផ្សាយ ស្តីពីការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការធ្វើចំណាកស្រុកដោយសុវត្ថិភាព តាមរយៈកិច្ចប្រជុំ វេទិកាសាធារណៈ ការអនុវត្តគោលនយោបាយ "ភូមិ-ឃុំ មានសុវត្ថិភាព" និងកម្មវិធីផ្សេងៗ ដល់មន្ត្រីរាជការ សិស្សានុសិស្ស លោកគ្រូ-អ្នកគ្រូ សាសនិកជន និងប្រជាពលរដ្ឋ សរុបចំនួន ១០.៣៦៥លើក មានអ្នកចូលរួមសរុបចំនួន ៤២៨.១៦៤នាក់ (ធៀបនឹងខែកុម្ភៈ មានចំនួន ៤៦៤.៣៦០នាក់ គឺមានការថយចុះចំនួន៣៦.១៩៦នាក់ ស្មើនឹង៧,៧៩%) ក្នុងនោះស្ត្រីចំនួន ២៣៩.៩៧០នាក់ ដូចមានតារាងលម្អិតខាងក្រោម៖ ၉ BT ត

# តារាងទិន្នន័យការអប់រំផ្សព្វផ្សាយតាមរយៈកិច្ចប្រជុំ និងវេទិកាសាធារណៈ

| ល.រ | ក្រសួង ស្ថាប័ន | ផ្សព្វផ្សាយ | | | វេទិកាសាធារណៈ | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួនដង/លើក | ចំនួនមនុស្ស | ចំនួនស្ត្រី | ចំនួនដង/លើក | ចំនួនមនុស្ស | ចំនួនស្ត្រី |
| ក្រសួង ស្ថាប័ន | | | | | | | |
| ១ | អគ្គស្នងការដ្ឋាននគរបាលជាតិ | ៤២ | ២.២០៧ | ១.២២១ | ៥៥៦ | ២៩.៩១៦ | ១៦.២៤១ |
| | សរុប ក្រសួង ស្ថាប័ន | ៤២លើក | ២.២០៧នាក់ | ១.២២១នាក់ | ៥៥៦លើក | ២៩.៩១៦នាក់ | ១៦.២៤១នាក់ |
| រាជធានី-ខេត្ត | | | | | | | |
| ១ | រាជធានីភ្នំពេញ | | | | | | |
| ២ | ខេត្តកណ្ដាល | ៥៩៥ | ៣៧.០៤៧ | ១៨.០១២ | ៥៦៥ | ១៧.៩៣៩ | ៨.២៤៤ |
| ៣ | ខេត្តបាត់ដំបង | ៧៦៤ | ២៦.៨១៩ | ១៤.៩៣៦ | ៥៣៦ | ១៥.៣៥៥ | ៨.៦២៥ |
| ៤ | ខេត្តពោធិ៍សាត់ | ៣៨៥ | ១៤.៩០៦ | ៧.៥១៧ | ៩៤ | ៣.៤២៦ | ១.៦១៥ |
| ៥ | ខេត្តសៀមរាប | ៤៦៣ | ២០.៥៤៣ | ១២.៨៤២ | ១៥២ | ៤.៧៨៧ | ២.៦៦៨ |
| ៦ | ខេត្តកំពង់ឆ្នាំង | ១.២៧៦ | ៤២.៨៧១ | ២២.៩៨៨ | ៧៦៣ | ១៨.៩៨៤ | ១០.៥៥៥ |
| ៧ | ខេត្តកំពង់ចាម | ២.០៧៧ | ១១០.៨២៨ | ៦៥.៨៦២ | ១.៣០៨ | ៥១.៦៤៧ | ៣៣.០៩៣ |
| ៨ | ខេត្តព្រះសីហនុ | ៥ | ១៩៣ | ១០១ | | | |
| ៩ | ខេត្តព្រះវិហារ | ១ | ៦៦ | ១៣ | | | |
| ១០ | ខេត្តស្វាយរៀង | | | | ៣៣២ | ១០.៥៧០ | ៥.៨០២ |
| ១១ | ខេត្តប៉ៃលិន | ៥៥ | ១.១៣៩ | ៣៨៧ | ៣១ | ១.៣៥២ | ៤៤៥ |
| ១២ | ខេត្តកោះកុង | | | | ៤៥ | ៩៨៤ | ៤៩៤ |
| ១៣ | ខេត្តកំពត | ៩ | ៣២៣ | ១៩៣ | ៩ | ៣០៣ | ១៨០ |
| ១៤ | ខេត្តកំពង់ធំ | | | | | | |
| ១៥ | ខេត្តតាកែវ | | | | | | |
| ១៦ | ខេត្តក្រចេះ | ៣៩ | ២.១៩២ | ១.២១២ | | | |
| ១៧ | ខេត្តកែប | ២៤ | ១.៥៧៤ | ៦៥៤ | | | |
| ១៨ | ខេត្តកំពង់ស្ពឺ | ២៣១ | ១០.៩០៩ | ៥.៤៧៥ | ៥ | ៣០៧ | ៩៦ |
| ១៩ | ខេត្តស្ទឹងត្រែង | | | | | | |
| ២០ | ខេត្តរតនគិរី | | | | | | |
| ២១ | ខេត្តព្រៃវែង | | | | | | |
| ២២ | ខេត្តត្បូងឃ្មុំ | ៣ | ៩៧៧ | ៥៣៩ | | | |
| ២៣ | ខេត្តបន្ទាយមានជ័យ | | | | | | |
| ២៤ | ខេត្តឧត្តរមានជ័យ | | | | | | |
| ២៥ | ខេត្តមណ្ឌលគិរី | | | | | | |
| | សរុប រាជធានី-ខេត្ត | ៥.៩២៧លើក | ២៧០.៣៨៧នាក់ | ១៥០.៦៩១នាក់ | ៣.៨៤០លើក | ១២៥.៦៥៤នាក់ | ៧១.៨១៧នាក់ |

| សរុបរួម ក្រសួង ស្ថាប័ន និងរាជធានី-ខេត្ត | ចំនួន | ចំនួនមនុស្សសរុប | ចំនួនស្ត្រី |
|---|---|---|---|
| | ១០.៣៦៥ លើក | ៤២៨.១៦៤ នាក់ | ២៣៩.៩៧០ នាក់ |

### ខ.១.២. ការផ្សព្វផ្សាយរបស់អង្គការដៃគូ

| អង្គការ | សកម្មភាព | ចំនួន ដង/លើក | ចំនួន មនុស្ស | ចំនួន ស្រី |
|---|---|---|---|---|
| APLE (ខេត្តសៀមរាប) | ផ្សព្វផ្សាយ អំពីការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអនឡាន ដល់ក្រុមគោលដៅយុវជន និងកុមារនៅក្នុងអង្គការដៃគូ។ | ០២ | ២៣ | ១៤ |
| មូលនិធីអេ២១ (ខេត្តសៀមរាប) | ផ្សព្វផ្សាយអំពីសិទ្ធិកុមារ និងអំពើជួញដូរមនុស្ស ដល់កុមារតាមដងផ្លូវ និងសហគមន៍។ | ០៨ | ៣១០ | ១៩៥ |
| បន្ទាយស្រី (ខេត្តសៀមរាប) | រៀបចំវេទិការកុមារស្តីពី ការទទួលបានការអប់រំសម្រាប់កុមារដែលធ្វើចំណាកស្រុក។ | ០១ | ១១ | ១០ |
| សរុប | | ១១ លើក | ៣៤៤ នាក់ | ២១៩ នាក់ |

## ខ.២. ការផ្សព្វផ្សាយតាមរយៈឧបករណ៍ ប្រព័ន្ធផ្សព្វផ្សាយ និងការចូលរួមជាវាគ្មិន

### ខ.២.១. ការផ្សព្វផ្សាយតាមរយៈឧបករណ៍(IEC)

- ក្រសួងអប់រំ យុវជន និងកីឡា សហការជាមួយក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដោយមានជំនួយឧបត្ថម្ភថវិកាពីអង្គការ Caritas, A21, SOLIDAR និងអង្គការ CWCC បានធ្វើការបោះពុម្ពសៀវភៅអប់រំ ស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងលំនាំបង្រៀន ចំនួន ៦.០០០ក្បាល សម្រាប់ការបង្រៀនសាកល្បង។
- អង្គការសាម៉ារីតាន់ភីស ខេត្តបន្ទាយមានជ័យ និងខេត្តបាត់ដំបង ចែកខិត្តប័ណ្ណផ្សព្វផ្សាយអំពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព ចំនួន ២.៣០១សន្លឹក។

### ខ.២.២. ការផ្សព្វផ្សាយតាមប្រព័ន្ធផ្សព្វផ្សាយ

- ខេត្តសៀមរាប៖ មន្ទីរព័ត៌មានខេត្ត បានធ្វើការផ្សព្វផ្សាយអប់រំ នៅក្នុងកម្មវិធីវិទ្យុជាតិនគរភ្នំ FM103 MHz និងទូរទស្សន៍ជាតិខេត្តសៀមរាប ស្តីពីការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាព និងការជួញដូរមនុស្ស តាមវិទ្យុ ៤៨ លើក (ផ្សាយផ្ទាល់១៩លើក និងចាក់ផ្សាយឡើងវិញ២៩លើក)។
- ខេត្តមណ្ឌលគិរី៖ មន្ទីរធម្មការ និងសាសនាខេត្ត បានធ្វើការផ្សព្វផ្សាយបញ្ជ្រាប តាមវិទ្យុ FM97MHz ក្នុងកម្មវិធី ព្រះពុទ្ធសាសនាផ្សាភ្ជាប់សង្គម ចំនួន ២០ថ្ងៃក្នុង១ខែ ស្មើនិង ២០លើក។

### ខ.២.៣. ការចូលរួមជាវាគ្មិន ក្នុងកម្មវិធីនានា

- ខេត្តកំពង់ចាម៖ ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមជាវាគ្មិនកម្មវិធីសន្ទនាមតិតាមវិទ្យុ ស្តីពីពលករចំណាកស្រុកប្រកបដោយសុវត្ថិភាព ០៤លើក។

## ខ.៣. ការបង្ការ ទប់ស្កាត់តាមវិធានការជំនាញ

### ខ.៣.១. ការធ្វើអធិការកិច្ច និងពង្រឹងប្រសិទ្ធភាពលើការអនុវត្តការងារ

- ខេត្តប៉ៃលិន៖ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានចុះធ្វើអធិការកិច្ចការងារ នៅតាមគ្រឹះស្ថានដែលមានការប្រើប្រាស់កម្លាំងពលកម្មដូចជា សែវឡូ កាស៊ីណូ ឡូតដ្ឋ និងអាហារដ្ឋាន ចំនួន ៨០កន្លែង ដោយរកពុំឃើញមានការកេងប្រវ័ញ្ច និងអំពើជួញដូរកម្លាំងពលកម្មទេ។

### ខ.៣.២. ការគ្រប់គ្រងស្ថិតិ៖ បច្ចុប្បន្នភាពចំណាកស្រុក

- អគ្គស្នងការដ្ឋាននគរបាលជាតិ

- ស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានធ្វើបច្ចុប្បន្នភាពទិន្នន័យប្រចាំខែ ចំពោះពលករចំណាកស្រុក ត្រឡប់មកពីក្រៅប្រទេសវិញ ទាំងស្របច្បាប់ និងមិនស្របច្បាប់ សរុបចំនួន ១០៩.៨៣៥នាក់ (ស្រី ៤៧.៨១៣នាក់) អនីតិជន២.៦៤៥នាក់។
- កម្លាំងជំនាញនៃស្នងការដ្ឋាននគរបាលខេត្តបាត់ដំបង បានធ្វើការងារបង្ការទប់ស្កាត់ពលរដ្ឋខ្មែរ ដែលធ្វើចំណាកស្រុកទៅក្រៅប្រទេស ដោយខុសច្បាប់បានចំនួន ០៩លើក មនុស្សចំនួន ៣០នាក់ (ស្រី ២៥នាក់) សមត្ថកិច្ចបានធ្វើកិច្ចសន្យាអប់រំ ណែនាំ រួចឱ្យត្រឡប់ទៅផ្ទះពួកគេវិញ។

**ខ.៣.៣. វិធានការបង្ការ ទប់ស្កាត់ តាមជំនាញគ្រប់គ្រងគោលដៅសង្ស័យបម្រើសេវាកម្មផ្លូវភេទ**

- អគ្គស្នងការដ្ឋាននគរបាលជាតិ
- ស្នងការដ្ឋាននគរបាលខេត្តកំពង់ធំ ក្រចេះ ស្ទឹងត្រែង ពោធិ៍សាត់ កោះកុង ព្រៃវែង ព្រះវិហារ រតនៈគិរី និងខេត្តតាកែវ បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានសកម្មភាពអាជីវកម្មផ្លូវភេទចំនួន ១០៨លើក។
- ស្នងការដ្ឋាននគរបាលខេត្តតាកែប ព្រះសីហនុ និងខេត្តកែប បានធ្វើបច្ចុប្បន្នភាពទិន្នន័យស្ថិតិ និងធ្វើកិច្ចសន្យាហាមឃាត់ការប្រព្រឹត្តបទល្មើសសញ្ចារកម្ម និងផ្សព្វផ្សាយ ច្បាប់ប្រឆាំងការជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ដល់ម្ចាស់អាជីវកម្ម ភោជនីយដ្ឋាន ផ្ទះសំណាក់ សណ្ឋាគារ ម៉ាស្សា ចំនួន ១៨២គោលដៅ មនុស្សចូលរួម ៧៣៥នាក់ (ស្រី ៦៥៩នាក់)។

**ខ.៣.៤. ការបង្ការ ទប់ស្កាត់ ការជួញដូរមនុស្សតាមរយៈការរៀបអាពាហ៍ពិពាហ៍រវាងពលរដ្ឋខ្មែរ និងជនបរទេស**

- ក្រសួងមហាផ្ទៃ

នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ (ក្រុមការងារអនុវត្តន៍ច្បាប់) បានធ្វើសម្ភាសន៍ពលរដ្ឋខ្មែរ និងជនបរទេសដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍ចំនួន ៣០គូ ដែលបានដាក់ពាក្យសុំរៀបអាពាហ៍ពិពាហ៍តាមផ្លូវច្បាប់ និងបានប្រមូលព័ត៌មានពីសុខទុក្ខនារីខែដែលរៀបការ ទៅរស់នៅក្រៅប្រទេសតាមរយៈការទំនាក់ទំនងតាមទូរស័ព្ទចំនួន ០១នាក់(ប្រទេសកូរ៉េ) មានសេចក្តីសុខសប្បាយជាធម្មតា។

## ខ.៤. កិច្ចការពារកុមារ ពីទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ

- ខេត្តព្រះសីហនុ៖ បន្តសហការជាមួយអង្គការម្លប់តាប៉ាង ធ្វើការទំនាក់ទំនងជាប្រចាំជាមួយបណ្តាញដែលបានដាក់ចំនួន ១.១៣៣នាក់ (ម៉ូតូឌុប ក្រុមម៉ូតូកង់បី ផ្ទះសំណាក់ សណ្ឋាគារ អ្នកលក់តាមឆ្នេរសមុទ្រ ភ្នាក់ងារទេសចរណ៍ និងសហគមន៍) ដើម្បីទប់ស្កាត់ទេសចរណ៍ផ្លូវភេទលើកុមារ។
- ខេត្តក្រចេះ៖ កុមារមករស់នៅភូមិកុមារកម្ពុជា SOS សរុបចំនួន ៨៩នាក់ (ស្រី ៣៩នាក់) ហើយមន្ទីរសង្គមកិច្ចខេត្ត បានចុះអធិការកិច្ចចំនួន ០២លើក។

# គ. ប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ឆ្លើយតបទៅនឹងអំពើជួញដូរមនុស្ស

## គ.១. ការងារអនុវត្តច្បាប់

លទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ខាងក្រោមនេះទទួលបានពីនាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត។

### គ.១.១. ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ

អគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថលើផ្ទៃប្រទេស និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានតាមដានស្រាវជ្រាវ បង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបបាន ៣១/៣៩ករណី(ធៀប

នឹងខែកុម្ភៈ មានចំនួន ៣៩ករណី ថយចុះចំនួន ០៨ករណី)ស្មើនឹង២៥,៨០% ឃាត់ខ្លួនជនសង្ស័យបញ្ជូនទៅសាលាដំបូងចំនួន ៤៥នាក់ (ស្រី ០៤នាក់) ក្នុងនោះជនសង្ស័យជាអនីតិជន ០៣នាក់។

សង្គ្រោះជនរងគ្រោះ ចំនួន ៥៥នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ០៨នាក់ អាយុ១៥-១៧ឆ្នាំ ០៣នាក់ និងអាយុពី១៨ឆ្នាំឡើង ៤៤នាក់ (ប្រគល់ឱ្យមន្ទីរសង្គមកិច្ច ០០នាក់ និងប្រគល់ឱ្យគ្រួសារ ៥៥នាក់) ក្នុងនោះមានចែកជាៈ

១. ករណីអំពើជួញដូរមនុស្ស

បង្ក្រាបបាន ២៥/២៧ករណី (ថយ ០២ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ៣៩នាក់ (ស្រី ០៤នាក់) អនីតិជន ០៣នាក់។ សង្គ្រោះជនរងគ្រោះចំនួន ៤៩នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ០២នាក់ អាយុ១៥-១៧ឆ្នាំ ០៣នាក់ និងអាយុ១៨ឆ្នាំឡើង ៤៤នាក់ (ប្រគល់ឱ្យគ្រួសារ ៤៩នាក់)។

*តារាងស្ថិតិបទល្មើសជួញដូរមនុស្ស*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -ការនាំយកអនីតិជនជាអាទិ៍ចេញដោយមិនស្របច្បាប់ | ០១ | ០១ | ០១ |
| -ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន | ២៣ | ៤២ | ៣៥(អនី.២) |
| -ការទទួលយកមនុស្សដោយមានគោលដៅជួយដល់ជនល្មើស | ០១ | ០៦ | ០៣ |
| *សរុប* | *២៥ ករណី* | *៤៩ នាក់* | *៣៩ នាក់* |

២. ករណីអំពើធ្វើអាជីវកម្មផ្លូវភេទ

បង្ក្រាបបាន ០៦ករណី/១២ករណី (ថយចុះ ០២ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន ០៦នាក់ (ស្រី ០២នាក់) អនីតិជន ០១នាក់។ សង្គ្រោះជនរងគ្រោះចំនួន ០៦នាក់ មានៈ អាយុក្រោម១៥ឆ្នាំ ០៦នាក់ អាយុ១៥-១៧ឆ្នាំ ០០នាក់ និងអាយុ១៨ឆ្នាំឡើង ០០នាក់ (ប្រគល់ឱ្យគ្រួសារ ០៦នាក់)។

*តារាងស្ថិតិបទល្មើសអាជីវកម្មផ្លូវភេទ*

| បទល្មើស | ករណី | ជនរងគ្រោះ | ជនសង្ស័យ |
|---|---|---|---|
| -អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ | ០៥ | ០៥ | ០៥ (អនី.១) |
| -អំពើអាសប្រាំងអនីតិជនអាយុក្រោម១៥ឆ្នាំ | ០១ | ០១ | ០១ |
| *សរុប* | *០៦ នាក់* | *០៦ នាក់* | *០៦ នាក់* |

## ឃ. កិច្ចការពារជនរងគ្រោះ និងការផ្តល់សេវាគាំទ្រ

### ឃ.១. ការទទួល និងសម្ភាសន៍ពលករបញ្ជូនត្រឡប់តាមច្រកព្រំដែន (ផ្លូវគោក និងផ្លូវអាកាស) ដើម្បីកំណត់មុខសញ្ញាជនរងគ្រោះ

#### ឃ.១.១. ការទទួល និងសម្ភាសពលករបញ្ជូនត្រឡប់

- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តាមរយៈស្ថានតំណាងនៅបរទេស បានសង្គ្រោះឧបត្ថម្ភ និងជួយសម្រួលដល់ការធ្វើមាតុភូមិនិវត្តន៍ពលរដ្ឋខ្មែរ ដែលត្រូវបានកំណត់អត្តសញ្ញាណបឋមរកភាពរងគ្រោះ និងបានធ្វើការសន្និដ្ឋានបឋមថាជា ករណីស្នាក់នៅ និងធ្វើការងារដោយខុសច្បាប់ ឬសង្ស័យរងគ្រោះដោយអំពើជួញដូរមនុស្ស សរុបចំនួន ១៣នាក់ ក្នុងនោះមកពីប្រទេសចិន១២នាក់ សិង្ហបុរី ០១នាក់។
- អគ្គស្នងការដ្ឋាននគរបាលជាតិ(ក្រុមការងារអនុវត្តច្បាប់) បានទទួល និងសម្ភាសន៍ជនរងគ្រោះដែលវិលត្រឡប់មកពីក្រៅប្រទេសចំនួន២២នាក់(ស្រី១៧នាក់)មកពីចិន១៦នាក់(ស្រី)ឥណ្ឌូនេស៊ី០១នាក់

ម៉ាឡេស៊ី០៥នាក់(ស្រី០១នាក់) ក្រោយសម្ភាសន៍រកឃើញថាទៅតាមរយៈមេខ្យល់ស្គាល់អត្តសញ្ញាណ ០១នាក់ និង ទៅតាមរយៈមេខ្យល់មិនស្គាល់អត្តសញ្ញាណ២១នាក់។

- **ស្នងការដ្ឋាននគរបាលរាជធានី ខេត្ត**
ស្នងការដ្ឋាននគរបាលខេត្តកោះកុង បានទទួល និងសម្ភាសពលករខ្មែរ ដែលអាជ្ញាធរបរទេសចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញ តាមច្រកទ្វារព្រំដែនអន្តរជាតិកម្ពុជា-ថៃ ចំនួន ១០លើក មនុស្សចំនួន ២០នាក់(ស្រី ០៤នាក់ អនីតិជន ០៣នាក់)។

# III. ការលើកកម្ពស់សមត្ថភាព និងការសម្របសម្រួល

## ក. ការបណ្តុះបណ្តាល និងសិក្ខាសាលា

### ក.១. ការងារបណ្តុះបណ្តាល

#### ក.១.១.ការបណ្តុះបណ្តាលក្នុងប្រទេស

តារាងវគ្គបណ្តុះបណ្តាល

| សកម្មភាពរៀបចំវគ្គបណ្តុះបណ្តាល | ចំនួនវគ្គ | សិក្ខាកាមសរុប | សិក្ខាកាមជានារី |
|---|---|---|---|
| កំពត៖ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព នៅស្រុកកំពង់ត្រាច និងស្រុកបន្ទាយមាស។ | ០៤ | ១៥០ | ៦៩ |
| ខេត្តសៀមរាប៖ | | | |
| - មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត បានបើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលសម្រាប់ធ្វើការផ្សព្វផ្សាយតាមសាលារៀន និងក្នុងសិប្បកម្មឥដ្ឋ។ | ០១ | ២០ | ១៤ |
| - អង្គការAPLE បានបើកវគ្គបណ្តុះបណ្តាលតាមអនឡាញ ជាមួយបុគ្គលិកអង្គការចំនួន ០៧ ក្នុងខេត្តសៀមរាប ស្តីពីទម្រង់នៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមអនឡាញ។ | ០១ | ២៧ | ១៦ |
| - អង្គការមូលនិធិ២១អេ បានបើកវគ្គបណ្តុះបណ្តាល ស្តីពីសិទ្ធិ ការធ្វើចំណាកស្រុក និងអំពើជួញដូរមនុស្ស នៅតាមមូលដ្ឋាន និងសាលារៀន។ | ០៩ | ៦០០ | ២៤០ |
| - អង្គការបន្ទាយស្រី បានបើកវគ្គបណ្តុះបណ្តាលតាមអនឡាញ ស្តីពីកិច្ចការពារកុមារដល់បណ្តាញអង្គការដៃគូ។ | ០១ | ១១ | ១០ |
| សរុប | ១៦ វគ្គ | ៨០៨ នាក់ | ៣៤៩ នាក់ |

### ក.២. សិក្ខាសាលា

- **អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖** បានសហការជាមួយ អង្គការសង់គ្រាល់ រៀបចំសិក្ខាសាលាពិគ្រោះយោបល់លើកទី២ ស្តីពីដំណើរការជ្រើសរើសពលករប្រកបដោយក្រមសីលធម៌(និម្មិត)"Topic: 2nd Consultation Workshop on Eyhical Recruitment Process(Virtual)" តាមប្រព័ន្ធវីដេអូរ Zoom ក្រោមការដឹកនាំសម្របសម្រួលដោយលោកជំទាវឧត្តមសេនីយ៍ឯក **ប៊ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ ចំនួន ០១វគ្គ មានសិក្ខាកាមសរុបចំនួន **៥៧**នាក់។
- **ខេត្តសៀមរាប៖** បានរៀបចំសិក្ខាសាលា ស្តីពីគោលការណ៍ណែនាំក្នុងការដោះស្រាយវិវាទរបស់ពលករទេសន្តរប្រវេសន៍ និងគោលនយោបាយទេសន្តរប្រវេសន៍ការងារប្រទេសកម្ពុជា ឆ្នាំ២០១៩-២០២៣ ចំនួន ០១វគ្គ មានសិក្ខាកាមសរុប ៤៥នាក់ ស្រី ០៥នាក់។

## ខ. សន្និសីទ កិច្ចប្រជុំ ទស្សនកិច្ច និងជំនួបពិភាក្សាការងារ

### ខ.១. ក្នុងប្រជុំក្នុងប្រទេស និងក្រៅប្រទេស

- គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ)

លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញ៖

- ដឹកនាំកិច្ចប្រជុំពិភាក្សាតាមប្រព័ន្ធអនឡាញ ស្តីពីកិច្ចពិគ្រោះយោបល់លើការស្វែងរកការស្រាវជ្រាវ និងអនុសាសន៍ ស្តីពីការធ្វើសមាហរណកម្មឡើងវិញប្រកបដោយជោគជ័យ សម្រាប់ជនទេសន្តរប្រវេសន៍ ដើម្បីរួចផុតពីអំពើជួញដូរមនុស្ស ដែលរៀបចំសម្របសម្រួលដោយអង្គការ Winrock និងមានការចូលរួមពី តំណាងពីក្រុមការងារស្រាវជ្រាវពីប្រទេសអង់គ្លេស តំណាងអង្គការ USAID និងអង្គការដៃគូពាក់ព័ន្ធការងារជួយជនរងគ្រោះពីទេសន្តប្រវេសន៍ នៅសាលប្រជុំ គ.ជ.ប.ជ។
- លោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ រួមនិងលោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. **ប៉ុណ្ណ សំខាន់** អគ្គលេខាធិការ គ.ជ.ប.ជ បានជួបប្រជុំពិភាក្សាការងារជាមួយតំណាងអង្គការសម្ព័ន្ធចាប់ដៃ ស្តីអំពីកិច្ចសហប្រតិបត្តិការ លើកិច្ចការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសលាប្រជុំគ.ជ.ប.ជ។

- **អគ្គលេខាធិការដ្ឋានគ.ជ.ប.ជ៖**

- បានរៀបចំកិច្ចប្រជុំពិភាក្សា តាមប្រព័ន្ធវីដេអូអនឡាញ ដែលរៀបចំនិងសម្របសម្រួលដោយ ASEAN-ACT ជាមួយតំណាងពីក្រសួងយុត្តិធម៌ តំណាងអង្គការដៃគូពាក់ព័ន្ធ មានASEAN-ACT និងពីអង្គការពីប្រទេសពាក់ព័ន្ធមួយចំនួន ដើម្បីកែសម្រួលលើរបៀបមួយចំនួន ត្រៀមមុនកិច្ចប្រជុំលើកម្រងឯកសារ សិក្ខាសាលា ASEAN-ACT ស្តីពី"ការឆ្លើយតប យុត្តិធម៌សម្រាប់ការជួញដូរមនុស្សតាមច្បាប់ថ្មីសិក្ខាសាលាទី៦ ក្រោមប្រធានបទវិធីសាស្ត្ររបស់ ស្ត្រីក្នុងតួនាទីជាអ្នកសម្របសម្រួល និងជួយកាត់បន្ថយគម្លាតសមភាពយេនឌ័រក្នុងការ ឆ្លើយតបការជួញដូរមនុស្ស"ក្រោមអធិបតីភាព **លោកជំទាវ អនុប្រធានអចិន្ត្រៃយ៍** គ.ជ.ប.ជ។
- បានរៀបចំកិច្ចប្រជុំពិភាក្សាតាមប្រព័ន្ធវីដេអូអនឡាញ ដើម្បីកែសម្រួលកិច្ចប្រជុំលើកម្រងឯកសារ សិក្ខាសាលា ASEAN-ACT ស្តីពី "ការឆ្លើយតប ដោយយុត្តិធម៌សម្រាប់ការជួញដូរមនុស្សតាមច្បាប់ថ្មីសិក្ខាសាលាទី៦ ក្រោមប្រធានបទ វិធីសាស្ត្ររបស់ស្ត្រីក្នុងតួនាទីជាអ្នកសម្របសម្រួល និងជួយកាត់បន្ថយគម្លាតសមភាពយេនឌ័រក្នុងការឆ្លើយតបការជួញដូរមនុស្ស" ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ។

## គ. ការងារសម្របសម្រួល

ការងាររៀបចំដឹកនាំសម្របសម្រួលកិច្ចប្រជុំ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅទូទាំងប្រទេសគឺ **៧១**លើក មានអ្នកចូលរួមសរុប ៤៦៨នាក់ (ស្រី **១០៨**នាក់) ក្នុងនោះគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស **៣៩**លើក និងលេខាធិការដ្ឋានរាជធានី-ខេត្ត ចំនួន **៣២**លើក។ (**ឧបសម្ព័ន្ធ១**)

# IV. ការសន្និដ្ឋានវាយតម្លៃ

## ក.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែង របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រេចការងារជាលទ្ធផលជោគជ័យគួរឱ្យកត់សម្គាល់៖

- ការគាំទ្ររបស់រាជរដ្ឋាភិបាល បានកំណត់យកបញ្ហាជួញដូរមនុស្សជាការងារសំខាន់ដែលត្រូវយកចិត្តទុកដាក់ និងផ្តល់អាទិភាពរកដំណោះស្រាយ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងថ្នាក់អន្តរជាតិផងដែរ។
- ការយកចិត្តទុកដាក់របស់ប្រមុខរាជរដ្ឋាភិបាលកម្ពុជា សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានផ្តល់អនុសាសន៍ ០៤ចំណុច និងវិធានការ ០៦ចំណុច របស់សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាប្រធាន គ.ជ.ប.ជ គឺជាប្រទីបដ៏ល្អដល់គ.ជ.ប.ជ និងគ្រប់សមាសភាពដែលជាយន្តការក្នុងការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- យើងមានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមព្រហ្មទណ្ឌ ក្រមនីតិវិធីព្រហ្មទណ្ឌ និងបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមូលដ្ឋានបង្អែក សម្រាប់ការអនុវត្តទប់ទល់ទៅនឹងបទល្មើសទាំងឡាយដែលកើតឡើង។
- យើងបានចុះសន្ធិសញ្ញា បត្យាប័ន អនុសញ្ញា អនុស្សរណៈនៃការយោគយល់គ្នា កិច្ចព្រមព្រៀង និងលិខិតបទដ្ឋានគតិយុត្តិជាច្រើនផ្សេងទៀត ជាមួយប្រទេសជិតខាងក្នុងតំបន់ និងសកលលោក លើវិស័យប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អំពើពេស្យាចារ រំលោភផ្លូវភេទ ជួញដូរស្ត្រី និងកុមារ...។ល។
- យើងមានយន្តការថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ដែលជាកម្លាំងស្នូលក្នុងការអនុវត្តការងារ។ ហើយតាមក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជន សុទ្ធតែបានចូលរួមយ៉ាងសកម្មក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើអសកម្មទាំងឡាយក្នុងសង្គមកម្ពុជា។
- ការកៀងគរកម្លាំង និងការជួយឧបត្ថម្ភពីអង្គការជាតិ អន្តរជាតិ វិស័យឯកជន និងថវិកាតាមក្រសួង ស្ថាប័ន អង្គភាពរៀបចំសម្រាប់ការអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

## ខ. ចំណុចខ្វះខាត ឬភាពប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង យើងពិនិត្យឃើញនៅមានចំណុចប្រឈម និងសេសសល់មួយចំនួនដូចជាៈ

- ក្រសួង ស្ថាប័ន អង្គភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សម្រាប់ជាយន្តការក្នុងការសហការ និងសហប្រតិបត្តិការគ្នា តែអង្គភាពមួយចំនួននៅមិនទាន់ចេះសហការគ្នាជាប្រព័ន្ធ និងបែងចែកការទទួលខុសត្រូវបន្តរហូតចប់ការងារ។
- ការធ្វើរបាយការណ៍នៅយឺតយ៉ាវ របាយការណ៍ភាគច្រើនមិនបានសម្រិតសម្រាំងឱ្យចេញពីសកម្មភាពអំពើជួញដូរមនុស្ស។
- មន្ត្រីយើងនៅមិនទាន់យល់ច្បាស់ពីប្រភេទការងារណា ដែលទាក់ទងនឹងអំពើជួញដូរមនុស្ស ដូចនេះពេលខ្លះយើងខ្វះអ្នកសហការ។

## គ. សំណូមពរ

- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការដៃគូត្រូវយកចិត្តទុកដាក់ទំនាក់ទំនង សហប្រតិបត្តិការ និងសាមគ្គីធ្វើការងារជាប្រព័ន្ធតាមជំនាញរៀងៗខ្លួន។
- ស្នើសុំគ្រប់ក្រសួង ស្ថាប័ន អង្គភាព និងអ្នកពាក់ព័ន្ធ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់រាល់កិច្ចប្រជុំប្រចាំខែ របស់ក្រុមការងារអន្តរជំនាញ តាមវិស័យនីមួយៗ ដើម្បីប្រសិទ្ធភាពការងារ។
- ស្នើឱ្យលេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ផ្តល់របាយការណ៍ឱ្យបានទៀងទាត់ ប្រចាំខែ ត្រីមាស ឆមាស និងប្រចាំឆ្នាំ។
- បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ឲ្យយល់ពីការងារដែលទាក់ទងនឹងអំពើជួញដូរមនុស្ស តាមវិស័យនីមួយៗរបស់ខ្លួន។

- ស្នើសុំក្រសួង ស្ថាប័ន អង្គភាពទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ យកចិត្តទុកដាក់អនុវត្តតាមសេចក្តីសម្រេច ស្តីពីការតែងតាំងសមាសភាពក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលប្រធាន គ.ជ.ប.ជ បានសម្រេច។

**ឃ. សន្និដ្ឋាន**

ការតាមដានត្រួតពិនិត្យ ត្រូវបានធ្វើឡើង ៖

- យើងមានការគាំទ្រ និងការយកចិត្តទុកដាក់ពីថ្នាក់ដឹកនាំ គ.ជ.ប.ជ និងរាជរដ្ឋាភិបាលនៃប្រទេសកម្ពុជា។ គោលនយោបាយល្អ និងការប្តេជ្ញាចិត្តខ្ពស់ មានឆន្ទៈមោះមុត មានសាមគ្គីភាព កិច្ចសហការប្រតិបត្តិការល្អ នោះយើងនឹងសម្រេចបាននូវលទ្ធផលជាទីគាប់ចិត្ត រួមកាត់បន្ថយបាននូវអំពើអសកម្មក្នុងសង្គម។
- ពីមួយថ្ងៃទៅមួយថ្ងៃមន្ត្រីយើងកាន់តែយល់ដឹង កាន់តែមានជំនាញ មានបទពិសោធន៍ ការងារកាន់តែស៊ីជម្រៅ ការទំនាក់ទំនងថ្នាក់ជាតិ និងអន្តរជាតិ កាន់តែច្រើន ធ្វើឱ្យយើងកាន់តែមើលឃើញនូវភាពខ្វះចន្លោះក្នុងកិច្ចការ និងមើលឃើញនូវតម្រូវការ ទាំងធនធានមនុស្ស សម្ភារ និងការចងក្រងលិខិតបទដ្ឋានគតិយុត្តនានា ដើម្បីសម្របសម្រួលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែមានប្រសិទ្ធភាព និងភាពរីកចម្រើន។
- បើយើងរៀបចំសកម្មភាព ផែនការអនុវត្ត និងផែនការយុទ្ធសាស្ត្របានល្អ យើងនឹងរៀបចំផែនការថវិកាកាន់តែប្រសើរសម្រាប់ការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រសិនបើប្រជាពលរដ្ឋដែលជាអ្នកទទួលសេវាមានការយល់ដឹងច្រើន ពីអំពើជួញដូរមនុស្ស មានការប្រុងប្រយ័ត្ន មិនលង់តាមការណែនាំ បោកបញ្ឆោតពីពួកឱកាសនិយម និងបានចូលរួមសហការជាមួយអ្នកបម្រើសេវា នៃក្រសួង ស្ថាប័ន អង្គភាព អ្នកពាក់ព័ន្ធជាតិ អន្តរជាតិ អង្គការ វិស័យឯកជននោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស កាន់តែទទួលបានជោគជ័យក្នុងសង្គមកម្ពុជាមិនខាន។

## V. ទិសដៅខែមេសា ឆ្នាំ ២០២១

ដើម្បីកែលម្អចំណុចខ្វះខាត និងពង្រឹងប្រសិទ្ធភាពនៃការអនុវត្តយុទ្ធសាស្ត្រទាំងបួន ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងរបៀបរបបការងារឱ្យកាន់តែល្អប្រសើរ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានដាក់ចេញនូវទិសដៅដូចខាងក្រោម ៖

១. បន្តពង្រឹងកិច្ចសហការទូលំទូលាយតាមរយៈការជួបប្រជុំពិភាក្សា បង្កើតសកម្មភាពផ្អែកលើយុទ្ធសាស្ត្ររួម ដែលបានកំណត់ និងចូលរួមបែងចែកភារកិច្ច ពង្រាយកម្លាំង និងការទទួលខុសត្រូវ ឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការ ទប់ស្កាត់ ឈានទៅលុបបំបាត់អំពើជួញដូរមនុស្សគ្រប់រូបភាព។

២. ពង្រឹងប្រសិទ្ធភាពនៃការអនុវត្តវិធានការជាអាទិភាព ដើម្បីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គ្រប់រូបភាព ជាអាទិ៍៖ អំពើជួញដូរ និងកេងប្រវ័ញ្ចកម្លាំងពលកម្ម ជួញដូរផ្លូវភេទ ការដកហូតសរីរាង្គជួញដូរ ការរត់ពន្ធទារក និងកុមារឆ្លងដែន ការពពោះជំនួស និងការជួញដូរពលកម្ម ក្នុងឧស្សាហកម្មនេសាទសមុទ្រ...។

៣. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល (ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការ ចែករំលែកការទទួលខុសត្រូវ និងការពារផលប្រយោជន៍ពលករ ជាពិសេសពលករក្នុងឧស្សាហកម្មនេសាទ ព្រមទាំងនិយោជក រវាងប្រទេសបញ្ជូន និងប្រទេសទទួលប្រកបដោយសមធម៌។

៤. គាំទ្រ ពង្រឹងសមត្ថភាពជំនាញពាក់ព័ន្ធគ្រប់ផ្នែក ដល់មន្ត្រីជំនាញ ពង្រឹងការគ្រប់គ្រង របៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី-ខេត្ត។

៥. បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធាន ដើម្បីលើកកម្ពស់ការយល់ដឹងជាសកល អំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាង

ទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀត ឱ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ ក្នុងសាលារៀន និងក្រៅសាលារៀន និងជនដែលងាយរងគ្រោះ។

៦. បន្តរៀបចំសកម្មភាពបណ្តុះបណ្តាល មន្ត្រីពាក់ព័ន្ធនឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ ព្រមទាំងចុះតាមដានការអនុវត្ត។

៧. បន្តតាមដានលទ្ធផល និងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគី ពហុភាគី និងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្សដែល សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខារួមគ្នា កាលពីថ្ងៃទី២១ ខែវិច្ឆិកា ឆ្នាំ២០១៥។

៨. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឱ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឱ្យបានត្រឹមត្រូវ។

៩. បន្តរៀបចំវិធានការ "គ្រប់គ្រងលំហូរ ពលករទេសន្តរប្រវេសន៍ការងារឆ្លងដែនមិនប្រក្រតី" (គោរពតាមអនុសាសន៍ដឹកនាំដ៏ខ្ពង់ខ្ពស់ សម្តេចក្រឡាហោម **ស ខេង** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ )។

១០. ពង្រឹងប្រព័ន្ធយុត្តិធម៌ព្រហ្មទណ្ឌ ជាពិសេសការពង្រឹងកិច្ចសហការក្នុងការជួយគ្នាទៅវិញទៅមក ក្នុងវិស័យយុត្តិធម៌ព្រហ្មទណ្ឌ ជាមួយប្រទេសពាក់ព័ន្ធ។

១១. បន្តអនុវត្ត និងចូលរួមយ៉ាងសកម្ម ក្នុងការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ។

១២. ជំរុញសាងសង់ជម្រកបណ្តោះអាសន្ន នៅតាមច្រកព្រំដែនសំខាន់ៗ ដែលមានការបញ្ជូនត្រឡប់ពីប្រទេសថៃ នៅតែមានជាប់បន្ត ជារៀងរាល់ថ្ងៃ ដោយមានមន្ត្រីប្រចាំការ សម្រាប់ការផ្តល់សេវាចាំបាច់មួយចំនួន ដូចជាការពិនិត្យ ព្យាបាលសុខភាពបឋម អាហារ សម្រាប់មនុស្សចាស់ កុមារ ទារក ការស្នាក់នៅបណ្តោះអាសន្ន មុនពេលចេញដំណើរ ការសាកសួរសុខទុក្ខ សម្របសម្រួល និងស្តាប់សំណូមពរដើម្បីបន្តដោះស្រាយនៅនឹងកន្លែង ឬ នៅតាមបណ្តាខេត្តប្រភពរបស់ពលករជាដើម។

ថ្ងៃ......................ខែ..........ឆ្នាំ ឆ្លូវ ត្រីស័ក ព.ស ២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី.......ខែ.......ឆ្នាំ២០២១
**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ_ប៊ុនអេង

**ចម្លងជូន**
- ខុទ្ទកាល័យ សម្តេចតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេចក្រឡាហោម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ

**"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"**
- ឯកឧត្តម លោកជំទាវ ប្រធានក្រុមការងារជំនាញ អន្តរក្រសួង ស្ថាប័ន
- សមាជិកក្រុមការងារគ.ជ.ប.ជ
- អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ

**"ដើម្បីជូនជ្រាប"**
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធទី១

## តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហប្រតិបត្តិការ (សរុបចំនួន ៧១លើក) មនុស្សចំនួន ៤៦៨នាក់ (ស្រី ១០៨នាក់)

| ស្ថាប័ន សម្របសម្រួល | សកម្មភាព |
| --- | --- |
| គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) | គណៈកម្មាធិការ គ.ជ.ប.ជ សម្របសម្រួលចំនួន ៣៩លើក អ្នកចូលរួមសរុបចំនួន ២៣នាក់ (ស្រី ០៧នាក់)<br>▪ លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ បានអញ្ជើញ៖<br>- ចូលរួមពិធីប្រគល់-ទទួលសម្ភារដែលឧបត្ថម្ភដោយកម្មវិធីអាស៊ាន-អូស្ត្រាលីប្រឆាំងការជួញដូរមនុស្ស(With compliment from ASEAN-ACT) ពីតំណាងអង្គការ ASEAN-ACT ប្រចាំកម្ពុជា នៅសាលប្រជុំគ.ជ.ប.ជ មានអ្នកចូលរួម ០៨នាក់ ស្រី០៤នាក់។<br>- ចូលរួម សកម្មភាពពិនិត្យ និងកែសម្រួលខ្លឹមសារសេចក្តីព្រាង សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារសុខភាពជនទេសន្តរប្រវេសន៍ថ្នាក់ជាតិ របស់ក្រសួងសុខាភិបាល នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ។<br>▪ លោកជំទាវ ឧត្តមសេនីយ៍ឯក វេជ្ជ. ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ បានអញ្ជើញ៖<br>- ដឹកនាំសកម្មភាពពិនិត្យ និងកែសម្រួលខ្លឹមសារអនុស្សរណៈយោគយល់រវាងគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអង្គការ We World Onlus នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ។<br>- ដឹកនាំពិនិត្យ និងធ្វើរបាយការណ៍ឆ្លើយតបទៅអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ស្តីពីសំណើសុំផ្តល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពដំណាក់កាលទី១ និងផ្តល់ធាតុចូលលើផែនការសកម្មភាពដំណាក់កាលទី២ នៃគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់ ២០១៧-២០៣០ នៅ គ.ជ.ប.ជ។<br>- ដឹកនាំសកម្មភាពពិភាក្សាផ្តល់ចម្លើយតបជូនទៅអង្គការគំនិតផ្តួចផ្តើមសកលប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានការចាត់តាំង(Global Initiative against Transnational Organized Crime)ទាំង១២សំណួរពាក់ព័ន្ធអំពើជួញដូរមនុស្ស នៅសាលប្រជុំ គ.ជ.ប.ជ។<br>- ដឹកនាំកិច្ចពិភាក្សាបំពេញបន្ថែមចូលទៅក្នុងឯកសារពីរប្រភេទ របស់ក្រសួងមហាផ្ទៃ ដើម្បីឆ្លើយតបក្នុងអនុសាសន៍នៃយន្តការពិនិត្យឡើងវិញតាមកាលកំណត់ជាសកល(UPR)ឆ្នាំ២០១៩ ជុំទី៣ និងឆ្លើយតបសេចក្តីសង្កេតសន្និដ្ឋាន នៃរបាយការណ៍ជាតិ ក្នុងការអនុវត្តអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍(ICERD) ដែលពាក់ព័ន្ធនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំ គ.ជ.ប.ជ។<br>▪ **លេខាធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖**<br>- លិខិតរបស់ គ.ជ.ប.ជ៖ លិខិតចេញ ១៩ច្បាប់ លិខិតចូល ១៤ច្បាប់។ |

- លិខិតរបស់ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ៖ លិខិតចេញ ១០ច្បាប់ លិខិតចូល ១២ច្បាប់។
- រៀបចំកិច្ចប្រជុំ និងធ្វើកំណត់ហេតុ រាល់ពេលប្រជុំ។
- បូកសរុបរបាយការណ៍ប្រចាំសប្តាហ៍ និងខែមីនា ឆ្នាំ២០២១ របស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។
- បូកសរុបរបាយការណ៍ខែមីនា ឆ្នាំ២០២១ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។
- ប្រមូលរបាយការណ៍ពីអន្តរក្រសួង ស្ថាប័ន និងរាជធានី/ខេត្តទាំង២៥។
- រៀបចំ និងបញ្ជូនលិខិតអញ្ជើញចូលរួមកិច្ចប្រជុំ ទៅកាន់ក្រសួង ស្ថាប័ន អង្គភាព រាជធានី-ខេត្ត និងអង្គការដៃគូពាក់ព័ន្ធនានា។
- ចងក្រងព័ត៌មាន រូបភាព និងសកម្មភាពថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិចូលក្នុងបណ្ណាសារវីគី ២៣សកម្មភាព។
- ស្រាវជ្រាវព័ត៌មានពាក់ព័ន្ធនឹងអំពើជួញដូរមនុស្ស ពីមជ្ឈដ្ឋានផ្សេងៗ ជាពិសេសព័ត៌មានដែលចុះផ្សាយ នៅក្នុងបណ្តាញសង្គម និងគេហទំព័រនានា។
- ព័ត៌មានស្រាវជ្រាវ ពីគេហទំព័រព័ត៌មាននានា រក្សាទុកក្នុងបណ្ណាល័យ Wiki ncct Convert ជា PDF បានចំនួន២៩ច្បាប់។

**▪ ក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់**

- ឯកឧត្តម អគ្គលេខាធិការរង៖ ១.បានអញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យ និងវាយតម្លៃការផ្តល់ពិន្ទុជូន គ.រ.ប.ជ/គ.ប.ខ.ជ ឆ្នាំ២០២០ នៅសាលប្រជុំ គ.ជ.ប.ជ មានអ្នកចូលរួម ២៤នាក់ ស្រី ០៣នាក់។ ២.បានចូលរួមពិភាក្សា ពិនិត្យ និងធ្វើរបាយការណ៍ឆ្លើយតបទៅអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ស្តីពីសំណើសុំផ្តល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពដំណាក់កាលទី១ និងផ្តល់ធាតុចូលលើផែនការ សកម្មភាពដំណាក់កាលទី២ នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់(២០១៧-២០៣០) ក្រោមការដឹកនាំសម្របសម្រួលដោយលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការគ.ជ.ប.ជ។ ៣.បានទទួលការចាត់តាំងដើម្បីដើម្បីចូលរួមកិច្ចប្រជុំតាមប្រព័ន្ធអនឡាញ ស្តីពីការបាត់ខ្លួនជនទេសន្តរប្រវេសន៍អំឡុងពេលទេសន្តរប្រវេសន៍អន្តរជាតិ ក្រោមការសម្របសម្រួលពីតំណាងអង្គការដៃគូមកពីប្រទេសពាក់ព័ន្ធមួយចំនួនផងដែរ។
- លោកប្រធានក្រុមជំនួយកិច្ចការបង្ការ ទប់ស្កាត់ បានអញ្ជើញចូលរួមក្នុងសិក្ខាសាលាពិគ្រោះយោបល់លើកទី២ ស្តីពីដំណើរការជ្រើសរើសពលករប្រកបដោយក្រមសីលធម៌(និម្មិត) Topic: 2nd Consultation Workshop on Ethical Recruitment Process (Virtual) តាមប្រព័ន្ធវីដេអូអនឡាញ ហ្សូម ក្រោមការដឹកនាំសម្របសម្រួលដោយ លោកជំទាវ ឧត្តមសេនីយ៍ ប៊ុណ្ណ សំខាន់ អគ្គលេខាធិការ គ.ជ.ប.ជ មានការរៀបចំសម្របសម្រួល ដោយអង្គការសង់គ្រាល់។

**▪ ក្រុមជំនួយកិច្ចការការពារជនរងគ្រោះ**

- ឯកឧត្តម អគ្គលេខាធិការរង បានអញ្ជើញចូលរួមកិច្ចប្រជុំ ពិភាក្សាការងារ ជាមួយអង្គការសម្ព័ន្ធចាប់ដៃ ស្តីពីកិច្ចសហប្រតិបត្តិការការពារជនរងគ្រោះ ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង រដ្ឋលេខាធិការ** ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។

| | |
|---|---|
| | ▪ **ក្រុមជំនួយកិច្ចការយុត្តិធម៌**<br>- ចូលរួមពិនិត្យ និងកែតម្រូវខ្លឹមសារសេចក្តីព្រាង MOU រវាងគ.ជ.ប.ជ និងអង្គការវើលអនលូស(WE WORLD ONLUS) ក្រោមការដឹកនាំដោយ **លោកជំទាវ អគ្គលេខាធិការ** នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- ចូលរួមពិនិត្យ និងកែសម្រួលខ្លឹមសារ "**សេចក្តីព្រាង សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារសុខភាពជនទេសន្តរប្រវេសន៍ថ្នាក់ជាតិ**" របស់ក្រសួងសុខាភិបាល ក្រោមការដឹកនាំសម្របសម្រួលដោយ **លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ** និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ និង**លោកជំទាវ អគ្គលេខាធិការ** នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- ចូលរួមពិនិត្យពិភាក្សា និងធ្វើរបាយការណ៍ឆ្លើយតបទៅអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ស្តីពីសំណើសុំផ្តល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពជំណាក់កាលទី១ និងផ្តល់ធាតុចូលក្នុងផែនការសកម្មភាពជំណាក់កាលទី២ នៃគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់(២០១៧២០៣០) ក្រោមការសម្របសម្រួលដោយ**លោកជំទាវ អគ្គលេខាធិការ** នៅអគ្គលេខាធិការដ្ឋានគ.ជ.ប.ជ។<br>- ចូលរួមពិភាក្សាផ្តល់ចម្លើយតបពាក់ព័ន្ធអំពើជួញដូរមនុស្ស ទាំង១២សំណួរ របស់អង្គការគំនិតផ្តួចផ្តើមសកលប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានការចាត់តាំង(Global Initiative against Transnational Organized Crime) ដឹកនាំសម្របសម្រួលដោយ **លោកជំទាវ អគ្គលេខាធិការ** នៅ គ.ជ.ប.ជ។<br>- បានពិនិត្យខ្លឹមសារពាក់ព័ន្ធអំពើជួញដូរមនុស្ស ដែលមាននៅក្នុងឯកសារពីរប្រភេទរបស់ក្រសួងមហាផ្ទៃបញ្ជូនមកដូចជា ឆ្លើយតបនូវអនុសាសន៍នៃយន្តការពិនិត្យឡើងវិញតាមកាលកំណត់ជាសកល(UPR)ឆ្នាំ ២០១៩ ជុំទី៣ ក្នុងនាមលោកជំទាវជាអនុប្រធានក្រុមការងារទទួលបន្ទុកសិទ្ធិមនុស្ស ក្រសួងមហាផ្ទៃ ដើម្បីប្រមូលធាតុចូលឆ្លើយតបទៅវិញ។<br>- ចូលរួមពិនិត្យ ពិភាក្សាផ្តល់ធាតុចូលបំពេញចម្លើយទៅក្នុងឯកសារទាំងពីរប្រភេទ របស់ក្រសួងមហាផ្ទៃខាងលើ នូវចំណុចណាដែលពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមការដឹកនាំសម្របសម្រួលដោយ**លោកជំទាវ អគ្គលេខាធិការ** នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>▪ **ក្រុមជំនួយកិច្ចការសហប្រតិបត្តិការអន្តរជាតិ**<br>- លោកជំទាវ ឧត្តមសេនីយ៍ទោ អគ្គលេខាធិការរង បានអញ្ជើញចូលរួម៖ ១.កិច្ចពិភាក្សាតាមប្រព័ន្ធអនឡាញនិងអនុសាសន៍ ស្តីពីការធ្វើសមាហរណកម្មឡើងវិញប្រកបដោយជោគជ័យ សម្រាប់ជនទេសន្តរប្រវេសន៍ ដើម្បីរួចផុតពីអំពើជួញដូរមនុស្ស ក្រោមអធិបតីភាពលោកជំទាវ **ជូ ប៊ុនអេង** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ជាមួយតំណាងពីក្រុមការងារស្រាវជ្រាវពីប្រទេសអង់គ្លេស តំណាងអង្គការ USAID និងអង្គការដៃគូពាក់ព័ន្ធការងារជួយជនរងគ្រោះពីទេសន្តរប្រវេសន៍ ដោយមានគាំទ្រពីគម្រោងអភិវឌ្ឍន៍របស់ USAID ក្នុងការអនុវត្តការងារនេះ។ ២.កិច្ចប្រជុំ ស្តីពីសកម្មភាពពិនិត្យ និងកែសម្រួលខ្លឹមសារសេចក្តីព្រាង សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារសុខភាពជនទេសន្តរប្រវេសន៍ថ្នាក់ជាតិរបស់ក្រសួងសុខាភិបាល ក្រោមការសម្របសម្រួលដោយ **លោកជំទាវ ឧត្តមសេនីយ៍ឯក** អគ្គលេខាធិការ គ.ជ.ប.ជ។ ៣.ពិភាក្សា ពិនិត្យ និងធ្វើរបាយការណ៍ឆ្លើយតបទៅអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ស្តីពីសំណើសុំផ្តល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពជំណាក់កាលទី១ និងផ្តល់ធាតុចូលលើផែនការសកម្មភាពជំណាក់កាលទី២ នៃគោលនយោបាយជាតិ ស្តីពីមនុស្សវ័យចាស់(២០១៧-២០៣០) ក្រោមសម្របសម្រួលដោយលោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ គ.ជ.ប.ជ។ ៤.ជំនួបកិច្ច |

| | |
|---|---|
| | ប្រជុំក្រុមអ្នកជំនាញក្នុងតំបន់ ស្តីពី"កិច្ចសហប្រតិបត្តិការជំរុញការធ្វើពាណិជ្ជកម្មរវាងវិស័យសាធារណៈ និងឯកជនដើម្បីប្រឆាំងការជួញដូរមនុស្សនៅអាស៊ីប៉ាស៊ីហ្វិក" ដែលមានការសម្របសម្រួលដោយអង្គការ UNODC។ ៥.សិក្ខាសាលាពិគ្រោះយោបល់លើកទី២ តាមវីដេអូ ZOOM ស្តីពីដំណើរការជ្រើសលករប្រកបដោយក្រមសិលធ៌ម(និម្មិត) ក្រោមការដឹកនាំសម្របសម្រួលរបស់**លោកជំទាវឧត្តមសេនីយ៍ឯក ប៉ុណ្ណ សំខាន់ អគ្គលេខាធិការ** ដែលរៀបចំសម្របសម្រួល ដោយអង្គការសង់ត្រាល់ នៅ គ.ជ.ប.ជ។ **៦.**កិច្ចប្រជុំពិភាក្សាតាមប្រព័ន្ធ Video Conference កែសម្រួលកិច្ចប្រជុំលើកម្រងឯកសារ សិក្ខាសាលាASEAN-ACT ស្តីពីការឆ្លើយតបដោយយុត្តិធម៌សម្រាប់ការជួញដូរមនុស្សតាមច្បាប់ថ្មី សិក្ខាសាលាទី៦ ក្រោមប្រធានបទ វិធីសាស្ត្ររបស់ស្ត្រីក្នុងតួនាទីជាអ្នកសម្របសម្រួល និងងជួយកាត់បន្ថយគម្លាតសមភាពយេនឌ័រក្នុងការឆ្លើយតបការជួញដូរមនុស្ស" ក្រោមអធិបតីភាព **លោកជំទាវ ជូ ប៊ុនអេង** រដ្ឋលេខាធិការ ក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍គ.ជ.ប.ជ ដែលរៀបចំ និងសម្របសម្រួលដោយអង្គការASEAN-ACT។<br>▪ **ក្រុមជំនួយកិច្ចការទេសន្តរប្រវេសន៍**<br>- ចូលរួមពិនិត្យ និងកែតម្រូវខ្លឹមសារសេចក្តីព្រាង MOU រវាង គ.ជ.ប.ជ និងអង្គការ វីវើលអនលូស (WE WORLD ONLUS) ក្រោមការដឹកនាំដោយ **លោកជំទាវឧត្តមសេនីយ៍ឯក អគ្គលេខាធិការ** នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- ចូលរួមពិនិត្យ និងកែសម្រួលខ្លឹមសារ "សេចក្តីព្រាង សេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារសុខភាពជនទេសន្តរប្រវេសន៍ថ្នាក់ជាតិ" របស់ក្រសួងសុខាភិបាល ក្រោមការដឹកនាំសម្របសម្រួលដោយ លោកជំទាវ រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ និង**លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ** នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- ចូលរួមពិនិត្យពិភាក្សា និងធ្វើរបាយការណ៍ឆ្លើយតបទៅអគ្គនាយកដ្ឋានរដ្ឋបាលក្រសួងមហាផ្ទៃ ស្តីពីសំណើសុំផ្តល់របាយការណ៍វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពជំណាក់កាលទី១ និងផ្តល់ធាតុចូលក្នុងផែនការសកម្មភាពជំណាក់កាលទី២ នៃគោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់ (២០១៧-២០៣០) ក្រោមការសម្របសម្រួលដោយ **លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ** នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ។<br>- ចូលរួមពិភាក្សាផ្តល់ចម្លើយតបពាក់ព័ន្ធអំពើជួញដូរមនុស្សទាំង១២សំណួរ របស់អង្គការគំនិតផ្តួចផ្តើមសកលប្រឆាំងនឹងឧក្រិដ្ឋកម្មឆ្លងដែនដែលមានការចាត់តាំង (Global Initiative against Transnational Organized Crime) ដឹកនាំសម្របសម្រួលដោយ **លោកជំទាវ ឧត្តមសេនីយ៍ឯក អគ្គលេខាធិការ** នៅគ.ជ.ប.ជ។<br>- ចូលរួមពិនិត្យខ្លឹមសារពាក់ព័ន្ធអំពើជួញដូរមនុស្សដែលមាននៅក្នុងឯកសារពីរប្រភេទរបស់ក្រសួងមហាផ្ទៃបញ្ជូនមកដូចជា៖ ១-សេចក្តីសង្កេតសន្និដ្ឋាននៃរបាយការណ៍ជាតិ ក្នុងការអនុវត្តអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងពូជសាសន៍ (ICERD) និង២-ឆ្លើយតបនូវអនុសាសន៍នៃយន្តការពិនិត្យឡើងវិញតាមកាលកំណត់ជាសកល(UPR)ឆ្នាំ ២០១៩ ជុំទី៣ ក្នុងនាមលោកជំទាវជាអនុប្រធានក្រុមការងារទទួលបន្ទុកសិទ្ធិមនុស្ស ក្រសួងមហាផ្ទៃ ដើម្បីប្រមូលធាតុចូលឆ្លើយតបទៅវិញ។<br>- ចូលរួមពិនិត្យ ពិភាក្សា ផ្តល់ធាតុចូលបំពេញចម្លើយទៅក្នុងឯកសារទាំងពីរប្រភេទរបស់ក្រសួងមហាផ្ទៃ នូវចំណុចណាដែលពាក់ព័ន្ធការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ក្រោមការដឹកនាំសម្របសម្រួលដោយ **លោកជំទាវឧត្តម សេនីយ៍ឯក អគ្គលេខាធិការ** នៅ គ.ជ.ប.ជ។ |
| **លេខាធិការដ្ឋាន គ.ឌ.ប.ជ សម្របសម្រួលចំនួន ៣២លើក អ្នកចូលរួមសរុបចំនួន ៤៤៥នាក់ (ស្រី ១០១នាក់)** | |

| | |
|---|---|
| ខេត្តកណ្ដាល | - គ.ខ.ប.ជ និងលេខាធិការដ្ឋាន ដឹកនាំដោយលោកជំទាវ ហ៊ុន កុសនី បានរៀបចំកិច្ចប្រជុំប្រចាំខែ ត្រីមាស ឆ្នាំ២០២១ តាមប្រព័ន្ធតេឡេក្រាម ចំនួន០១លើក អ្នកចូលរួម ៤១នាក់ ស្រី ២២នាក់។<br>- ក្រុមការងារក្រុង-ស្រុក បានប្រជុំប្រចាំខែ ចំនួន ០៥លើក អ្នកចូលរួមចំនួន ១៤០នាក់ ស្រី ៧២នាក់។<br>- ក្រុមការងារលេខាធិការដ្ឋានថ្នាក់ខេត្ត និងថ្នាក់ស្រុក បានចូលរួមកិច្ចប្រជុំពិភាក្សាតាមតេឡេក្រាម ជាមួយអង្គការសកម្មភាពដើម្បីកុមារ(APLE) ០១លើក ស្ដីពីការលើកកម្ពស់ការរាយការណ៍ករណីសង្ស័យនៃការកេងប្រវ័ញ្ចផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណិត។ |
| ខេត្តសៀមរាប | - បានដឹកនាំកិច្ចប្រជុំប្រចាំខែមីនា របស់ក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រុង ស្រុក ចំនួន ០១លើក អ្នកចូលរួមចំនួន ២៨នាក់ ស្រី ០២នាក់។<br>- សហការជាមួយរដ្ឋបាលខេត្តបន្ទាយមានជ័យ ស្ដីពីការផ្ទេរពលករខេត្តសៀមរាប មកពីប្រទេសថៃ ពីមណ្ឌលចត្តាឡីស័កខេត្តបន្ទាយមានជ័យ មកធ្វើចត្តាឡីស័កបន្តនៅខេត្តសៀមរាប ០១លើក។ |
| ខេត្តកំពង់ចាម | - លេខាធិការដ្ឋានខេត្ត ប្រជុំពង្រឹងសមត្ថភាពដល់មន្ត្រីយន្តការនៃ គ.ខ.ប.ជ ចំនួន ១០លើក អ្នកចូលរួមចំនួន ១៩១នាក់។<br>- បានចូលរួមសិក្ខាសាលាស្ដីពី គោលការណ៍ណែនាំក្នុងការដោះស្រាយវិវាទរបស់ពលករទេសន្តរប្រវេសន៍ និងគោលនយោបាយទេសន្តរប្រវេសន៍ការងារប្រទេសកម្ពុជា ២០១៩-២០២៣ នៅខេត្តសៀមរាប អ្នកចូលរួម ៤៥នាក់ ស្រី ០៥នាក់។ |
| ខេត្តកំពង់ធំ | - ឯកឧត្តមអភិបាលខេត្ត បានដឹកនាំក្រុមការងារគ.ខ.ប.ជ ខេត្ត ចុះសួរសុខទុក្ខពលករវិលត្រឡប់ពីប្រទេសថៃ ដែលត្រូវដាក់ក្នុងមណ្ឌលចត្តាឡីស័កតាមបណ្ដាក្រុង ស្រុកទាំង៩ ក្នុងខេត្ត និងបានចែកសម្ភារប្រើប្រាស់ ថវិកាមួយចំនួនផងដែរ។<br>- លោកជំទាវប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចូលរួមទទួលពលករវិលត្រឡប់ពីប្រទេសថៃ ០១លើក។ |
| ខេត្តបន្ទាយមានជ័យ | - ឯកឧត្តមអភិបាលខេត្ត បានចុះសំណេះសំណាលជាមួយប្រជាពលករដែលកំពុងធ្វើចត្តាឡីស័ក នៅមណ្ឌលចត្តាឡីស័កកងវ៉ា ០១លើក។<br>- លោកជំទាវប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចុះពិនិត្យមើលស្ថានភាពប្រជាពលករដែលបានវិលត្រឡប់ពីប្រទេសថៃ និងកំពុងធ្វើចត្តាឡីស័កនៅក្នុងក្រុងសេរីសោភ័ណ ចំនួន ០៩លើក។ |